អន្តរប្ញទី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទ៖ «ចិត្តជាទេវទត្ត មាត់ជាទេវតា» ។

**Website: www.hoksavann.org**

ថ្ងៃទី២១ កក្កដា ២០១០



ពាក្យថា «ចិត្តជាទេវទត្ត» ជាពាក្យមួយទាញយកន័យរបស់រឿងទេវទត្ត ដែលមានចិត្តព្យាបាទចងគំនុំនិងព្យាយាមធ្វើគត់ព្រះពុទ្ធជាម្ចាស់ដោយសេចក្តីច្រណែន ។ រឿងដោយសង្ខេបថា ព្រះអង្គម្ចាស់ទេវទត្តត្រូវជាព្រះញាតិរបស់ព្រះពុទ្ធ ដំបូងបានចូលបួសក្នុងសំណាក់ព្រះអង្គដោយសទ្ធាជ្រះថ្លា ។ ក្រោយមកមានចិត្តច្រណែន ភិក្ខុទេវទត្តបានប្រើមធ្យោបាយគ្រប់យ៉ាងដើម្បីបន្ថយកិត្តិយសព្រះពុទ្ធ រហូតប៉ងធ្វើគត់ព្រះអង្គទៀតផង ។ ដំបូងទេវទត្តបានប្រើមធ្យោបាយសន្តិវិធីជារបៀបប្រជាធិបតេយ្យ ដោយបញ្ញត្តិវិន័យឲ្យតឹងរ៉ឹងជាងព្រះពុទ្ធ ហើយប្រកាសថា បើភិក្ខុអង្គណាយល់ស្របតាមវិន័យដែលយើងបញ្ញត្តិថ្មីនេះ ចូរមកទៅនៅក្នុងព្រៃតាមយើង ។ ភិក្ខុទេវទត្តបញ្ញត្តិវិន័យថ្មីនេះមានជាអាទិថា ភិក្ខុបួសហើយត្រូវទៅនៅក្នុងព្រៃអស់មួយជីវិត ប្រើសំពត់បង្សុកូលអស់មួយជីវិត មិនឆាន់សាច់អស់មួយជីវិតជាដើម ។ តាមពិតដំបូងព្រះពុទ្ធបានអនុញ្ញាតឲ្យភិក្ខុដែលបួសហើយ ត្រូវនៅទៀបគល់ឈើអស់មួយជីវិត តែក្រោយមកគេមានសទ្ធាធ្វើកុដិប្រគេន ព្រះពុទ្ធបានអនុញ្ញាតម្តងទៀតហៅថាអនុបញ្ញត្តិ ព្រះភិក្ខុអាចទទួលគង់នៅបាន អាចទទួលត្រៃ-ចីវរដែលគេប្រគេន អាចឆាន់សាច់បានដោយបរិសុទ្ធដោយហេតុបីយ៉ាង គឺមិនឃើញគេសម្លាប់ មិនឮសត្វស្រែកពេលដែ-លគេសម្លាប់ និងមិនមានសេចក្តីសង្ស័យ ។ ពេលដែលឮភិក្ខុទេវទត្តប្រកាស ភិក្ខុខ្លះដែលមិនបានពិចារណាឲ្យយល់ការពិតក៏ជឿហើយទៅតាមភិក្ខុទេវទត្តជាច្រើនអង្គ ។ នេះជាទោសទី១របស់ភិក្ខុទេវទត្តដល់ថ្នាក់អនន្តរិយកម្ម គឺទោសបំបែកសង្ឃ ។ ទោសប្រទូស្តខ្លះទៀត គឺប្រមៀលដុំទម្លាក់លើព្រះពុទ្ធ ដើម្បីបន្ថយកំហឹងភិក្ខុទេវទត្ត ព្រះអង្គបានយកព្រះបាទទៅទ្រ ធ្វើឲ្យព្រះលោហិតចេញបន្តិច អំពើនេះក៏ត្រូវអនន្តរិយកម្មដែរ ។ មធ្យោបាយក្រៅពីនេះ ភិក្ខុទេវទត្តបានឲ្យគេលែងដំរីនាឡាគិរីឲ្យព្រួចព្រះអង្គ ។ ញុះញង់ព្រះបាទអជាតសត្រូវ ឲ្យធ្វើគត់ព្រះបាទពិម្ពិសារដែលជាព្រះបិតា ដើម្បីបានសោយរាជ្យពីក្មេង ឯភិក្ខុទេវទត្តខ្លួនឯងទៅធ្វើគត់ព្រះពុទ្ធ ។ ទីបំផុត ភិក្ខុទេវទត្តបានត្រូវវិនាសដោយការប្រទូស្តចំពោះព្រះពុទ្ធជាអ្នកឥតទោស ។ ដោយចិត្តរបស់ភិក្ខុទេវទត្តបែបនេះ ទើបពុទ្ធសាសនិកខ្មែរបានពោលចំពោះជនណាដែលមានចិត្តអាក្រក់បៀតបៀនអ្នកដទៃថាមានចិត្តអាក្រក់ដូចភិក្ខុទេវទត្ត ។

«មាត់ជាទេវតា» គឺជាសំដីទេវតា ជាសំដីទន់ភ្លន់ផ្អែមល្ហែមពិរោះពិសារ ជាសំដីអ្នកសប្បាយក្នុងកាមគុណ ។ បើទេវតាជាសម្មាទិដ្ឋិ ជាសំដីត្រឹមត្រូវពោលពាក្យពិត ។

«ចិត្តជាទេវទត្ត មាត់ជាទេវតា» សំដៅសេចក្តីថា ចិត្តខាងក្នុងពោរពេញដោយគំនិតព្យាបាទ តែសំដីខាងក្រៅទន់ភ្លន់សុភាពរាបសា ដើម្បីលាក់បាំងគំនិតអាក្រក់បែបណាមួយ ។ ពាក្យនេះមានភាពត្រឹមត្រូវទៅលើមនុស្សមួយភាគនៅក្នុងសង្គមមនុស្ស ដែលមានបំណងប្រព្រឹត្តអាក្រក់ទៅលើបុគ្គលណាម្នាក់ ឬប្រទេសណាមួយ ក៏បិទបាំងការពិតដោយសំដីល្អខាងក្រៅ ។ បានជាមានពាក្យខ្មែររំលឹកថា កុំអាលជឿសំដីខាងក្រៅ ត្រូវពិចារណាឲ្យដឹងការពិតសិន ។ ពាក្យខ្មែរមួយទៀតពោលថា កុំទុកចិត្តអភិប្រាយ គឺកុំទុកចិត្តជឿអ្នកពូកែនិយាយព្រោកប្រាជ្ញហូរដូចទឹក តែជាសំដីគ្មានខ្លឹមសារ គ្មានប្រយោជន៍អ្វីឡើយ ។ ក្នុងកាលាបសូត្រ ព្រះពុទ្ធបានបង្រៀនមនុស្សកុំឲ្យជឿអាការៈ១០យ៉ាង មានមិនឲ្យជឿពាក្យនិយាយតៗគ្នា មិនឲ្យជឿអាការៈខាងក្រៅតាមកាយវិការ ឬតាមសំដីជាដើមឡើយ ព្រោះមានអ្នកក្លែងបន្លំ មុននឹងជឿបែបណា ត្រូវសង្កេតពិនិត្យពិចារណាឲ្យបានល្អិតល្អន់ជាមុនសិន ។ សូម្បីព្រះពុទ្ធជាបុគ្គលបរិសុទ្ធ ក៏ព្រះអង្គបើកឱកាសឲ្យដល់បុគ្គលគ្រប់គ្នា ដែលមកស្តាប់ព្រះអង្គ ឲ្យពិចារណាឲ្យបានម៉ត់ចត់មុននឹងជឿពាក្យរបស់ព្រះអង្គ ។ មុននឹងជឿអ្នកជំនួញដែលឃោសនា ត្រូវពិចារ-ណា ព្រោះអ្នកជំនួញចេះតែឃោសនាទំនិញរបស់ខ្លួនមានគុណភាពខ្ពស់ ដើម្បីបញ្ចុះបញ្ចូលអ្នកទិញ ។ អ្នកស្តីដណ្តឹងកូនក្រមុំគេ ចេះតែនិយាយលើកតម្លៃកូនប្រុសរបស់ខ្លួនហួសពីការពិត ដើម្បីបញ្ចុះបញ្ចូលឲ្យគេឲ្យកូនក្រមុំគេមកកូនខ្លួន ។ អ្នកនយោបាយនិយាយឃោសនាផានាបែបនេះបែបនោះ ដើម្បីឲ្យប្រជាពលរដ្ឋបោះឆ្នោតឲ្យខ្លួន ។ បានជាលោកឲ្យពិចារណាគ្រប់អាការៈខាងក្រៅរបស់មនុស្ស ព្រោះមានមនុស្សខ្លះចិត្តខាងក្នុងនិងសំដីខាងក្រៅដូចគ្នា ផ្ទុយទៅវិញមានមនុស្សមួយភាគចិត្តអាក្រក់សំដីខាងក្រៅល្អ ដើម្បីបោកបញ្ឆោតឲ្យគេជឿខុស ដោយត្រូវប្រយ័ត្នបំផុត គឺជនបរទេសនិងអ្នកនយោបាយ ។ «ចិត្តជាទេវទត្ត មាត់ជាទេវតា» បង្រៀនឲ្យមនុស្សគ្រប់រូបប្រុងប្រយ័ត្ន កុំជឿត្រឹមតែអាការៈខាងក្រៅ តែត្រូវពិនិត្យមើលសកម្មភាព ។៚